[EMBARGOED FOR: 00:01 GMT, 26 September 2008] Public

# អង្គការលើកលែងទោសអន្តរជាតិ

# ការងារដ៏គ្រោះថ្នាក់

## ការការពារសិទ្ធិមានលំនៅដ្ឋាននៅកម្ពុជា



AI Index: ASA 23/014/2008

INTERNATIONAL SECRETARIAT, 1 EASTON STREET, LONDON WC1X 0DW, UNITED KINGDOM

# មាតិកា


សេចក្តីផ្តើម........................................................................ ១

តើអ្នកណាជាអ្នកការពារសិទ្ធិមនុស្ស? ................................................ ៣

សេរីភាពសំរាប់ការការពារសិទ្ធិមនុស្សកាន់តែចង្អៀតទៅ............................ ៥

    អ្នកតំណាងសហគមន៍ប្រឈមនឹងគ្រោះថ្នាក់ ......................................៥

    ខេត្តបាត់ដំបង:   ការចាប់ខ្លួនតាមទំនើងចិត្តនិងសវនាការអយុត្តិធម៌........... ៥

    លំនាំនៃការចាប់ខ្លួននិងការវិនិច្ឆ័យដោយអយុត្តិធម៌..................... ៨

    ការគំរាមចាប់ខ្លួននិងឃុំឃាំង........................................ ១០

មន្ត្រីសិទ្ធិមនុស្ស................................................................. ១៤

    អ្នកឃ្លាំមើលសិទ្ធិមនុស្ស................................................ ១៤

    មេធាវីជំនួយផ្នែកច្បាប់.......................................................... ១៩

សេចក្តីសន្និដ្ឋាន...........................................................................២០

អនុសាសន៍..................................................................................២២

# ការខាររដ៏គ្រោះថ្នាក់ -
# ការការពារសិទ្ធិមានលំនៅដ្ឋាននៅកម្ពុជា

## សេចក្តីផ្តើម

អ្នកការពារសិទ្ធិមនុស្សធ្វើសកម្មភាពជាបុគ្គលឬចូលរួមជាមួយអ្នកផ្សេងទៀត ដើម្បីលើកកំពស់ឬការពារសិទ្ធិមនុស្សដោយមធ្យោបាយអហិង្សានិងសន្តិវិធី។ ពួកគេដើរតួនាទីដ៏សំខាន់ក្នុងការការពារនិងលើកកំពស់សិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ប្រជាជនកម្ពុជានិងសិទ្ធិផ្សេងៗទៀត ដែលទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ រួមមានការបណ្តេញចេញដោយបង្ខំ។

នៅឆ្នាំ២០០៨ គេបានដឹងថាប្រជាជនកម្ពុជាប្រមាណ ១៥០.០០០ នាក់ដែលរស់នៅប្រឈមនឹងការបណ្តេញចេញដោយបង្ខំបន្ទាប់ពីមានជម្លោះដីធ្លី ការរំលោភដីធ្លី និងគំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនិងគំរោងអភិវឌ្ឍន៍ទីក្រុងឡើងវិញ។[១] នៅក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានបណ្តេញចេញដោយបង្ខំ ធ្វើអោយប្រជាជនមួយចំនួនគ្មានផ្ទះសម្បែង ហើយអ្នកដទៃទៀតត្រូវបានផ្លាស់ប្តូរទីលំនៅទៅកាន់ទីតាំងថ្មីដែលមានជំរោកមិនសមរម្យ ដែលខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ ខ្វះខាតសម្ភារៈប្រើប្រាស់ចាំបាច់ ដូចជាបញ្ហាអនាម័យ និងឱកាសទទួលបានការងារធ្វើ។ ក្នុងរបាយការណ៍ចេញផ្សាយនៅក្នុងខែកុម្ភៈឆ្នាំ២០០៨ អង្គការលើកលែងទោសអន្តរជាតិ បានបង្ហាញនូវវិធីដែលអាជ្ញាធរខកខានមិនបានការពារដល់ប្រជាជន ទាំងតាមផ្លូវច្បាប់និងការអនុវត្តផ្ទាល់ ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ។ ផ្ទុយទៅវិញអ្នកដែលមានអំណាចនយោបាយឬសេដ្ឋកិច្ច ទាំងនោះបានប្រព្រឹត្តតាមទំនើងចិត្តដោយគ្មានទោស នូវការរឹបអូសយកដីធ្លី។ ពួកគេប្រព្រឹត្តដូច្នេះដោយសហការជាមួយអាជ្ញាធរមូលដ្ឋានតាមវិធីដែលចេញឈ្មោះកម្មសិទ្ធដីនិងការចេញបញ្ជាឱ្យបណ្តេញចេញដោយបង្ខំដែលមិនច្បាស់លាស់ និងការប្រើប្រព័ន្ធតុលាការខុសដើម្បីរារាំងជនរងគ្រោះមិនអោយការពារសិទ្ធិរបស់ពួកគេ។

មានការបង្ហាញអោយឃើញថាមានសញ្ញាថយចុះបន្តិចបន្តួច ក្នុងជម្លោះនៃការបណ្តេញចេញដោយបង្ខំ។ អង្គការលើកលែងទោសអន្តរជាតិដឹងថាមានជម្លោះដីចំនួន៦០ករណីនៅទូទាំងប្រទេសកម្ពុជា ដែលបានឈានជាករណីនាំមុខក្នុងអំឡុង៦ខែដំបូងនៃឆ្នាំ២០០៨ ដោយតាមរយៈការបណ្តេញចេញ ការប្រឆាំងតវ៉ា អំពើហិង្សា ឬករណីតុលាការ។ មាន១៣ករណីនៅក្នុងចំណោមករណីទាំងអស់នេះ

---

[១] សម្រាប់ការវិភាគស្តីពីប្រធានបទដ៏ទំលំទូលាយនៃការបណ្តេញចេញ សូមមើលរបាយការណ៍អង្គការលើកលែងទោសអន្តរជាតិៈ – *"សិទ្ធិមនុស្សត្រូវគេរំលោភ-ការបណ្តេញចេញដោយបង្ខំនៅព្រះរាជាណាចក្រកម្ពុជា"* ASA 23/02/2008.

គឺជាការបណ្តេញចេញដោយបង្ខំ ដែលគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធមិបានកំណត់ថាជា *"ការឱ្យរុះរើចេញជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ពីលំនៅដ្ឋាន ឬដីដោយប្រឆាំងនឹងឆន្ទៈរបស់បុគ្គល គ្រួសារឬសហគមន៍ ដែលពួកគេកាន់កាប់ ដោយគ្មានការផ្តល់ឬ ទទួលបាននូវការការពារតាមទំរង់ផ្លូវច្បាប់សមរម្យ ឬការការពារផ្សេងទៀតឡើយ"*។[២]

ការវាយតម្លៃជាបណ្តោះអាសន្នដោយផ្អែកលើប្រព័ន្ធផ្សព្វផ្សាយ សារព័ត៌មាន របាយការណ៍ផ្សេងៗ និងការប្រស្រ័យទាក់ទងជាមួយសកម្មជនដីធ្លី លើកឡើងថា យ៉ាងហោចណាស់មាន២៨០០ គ្រួសារឬ១៤.០០០នាក់ ត្រូវបានទទួលរងផលប៉ះពាល់ដោយសារការបណ្តេញចេញដោយបង្ខំទាំង ១៣ ករណីនេះ។

ក្នុងអំឡុងពេលដូចគ្នានេះ មានអ្នកភូមិយ៉ាងតិច៣៣នាក់ត្រូវបានចាប់ខ្លួន។ ១៤នាក់ក្នុង ចំណោមអ្នកទាំងនេះត្រូវបានដោះលែង ហើយអ្នកដែលនៅក្នុងពន្ធនាគារត្រូវបានចោទប្រកាន់អំពី បទល្មើស នៅក្រោមច្បាប់អ៊ុនតាក់[៣] និងក្រោមបទបញ្ញត្តិព្រហ្មទណ្ឌនៃច្បាប់ភូមិបាលឆ្នាំ២០០១ រួមមានកំហុសធ្វើអោយខូចខាតទ្រព្យសម្បត្តិ និងការរំលោភលើទ្រពសម្បត្តិអ្នកដទៃ។ អ្នកដែលឃុំខ្លួន មួយចំនួន គឺជាអ្នកភូមិធម្មតា អ្នកដទៃទៀត ខ្លះគឺជាតំណាងរបស់អ្នកភូមិជាផ្លូវការឬមិនផ្លូវការ ដែលអង្គការលើកលែងទោសអន្តរជាតិចាត់ទុកពួកគាត់ថាជាអ្នកការពារសិទ្ធិមនុស្ស។

រយៈពេលជាងពីរឆ្នាំកន្លងទៅនេះ អង្គការសិទ្ធិមនុស្សក្នុងស្រុកអាដហុក បានបូកសរុប ចំនួនសកម្មជនដីធ្លី ដែលគេចាប់ខ្លួនរួមមាន : ចំនួនបានកើនឡើងពី៧៨នាក់ក្នុងឆ្នាំ២០០៦ ដល់១៤៩នាក់ ក្នុងឆ្នាំ២០០៧។ កំណើននេះ គឺស្របទៅនឹងការកើនឡើងនៃចំនួនរបាយការណ៍ ដែលចោទថាប៉ូលិស បានចាប់សកម្មជនដីធ្លីដោយអយុត្តិធមិ ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ដែល មិនត្រឹមត្រូវទៅលើសកម្មជនទាំងនោះ និងមន្ត្រីប្រតិបត្តច្បាប់និងមន្ត្រីតុលាការបានគំរាមចាប់ដាក់គុក ប្រជាជនដែលតវ៉ាប្រឆាំងនឹងជម្លោះដីធ្លី។

អង្គការលើកលែងទោសអន្តរជាតិព្រួយបារម្ភថា វាគឺជានិន្នាការមួយ ដែលអ្នកមានទ្រព្យ និងអ្នកមានអំណាចកំពុងប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនកាន់តែខ្លាំងឡើង ដើម្បីបំបិទមាត់អ្នកប្រឆាំង

[២] គណៈកម្មាធិការទទួលបន្ទុកផ្នែកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធមិ អនុសាសន៍រួមទី៧ សម័យប្រជុំលើកទី១៦ (១៩៩៧) (៥៨):សិទ្ធិមានលំនៅ ដ្ឋានសមរម្យ (មាត្រាទី១១ ចំនុច១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធមិ:- ការបណ្តេញចេញដោយបង្ខំ កថាខ័ណ្ឌទី៣។

[៣] *បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល"* ឧត្តមក្រុមប្រឹក្សា ជាតិជាន់ខ្ពស់- សេចក្តីសម្រេចចិត្តនៅថ្ងៃទី១០ កញ្ញា ១៩៩២។

របស់ខ្លួន តាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ នៅពេលសំពាធលើដីធ្លីនិងក្រុមផ្សេងៗ បន្តធ្វើជំនួញដីធ្លី និងកង្វះខាតនៃច្បាប់ បានធ្វើឱ្យសេរីភាពបំពេញការងាររបស់អ្នកការពារសិទ្ធិមនុស្សកាន់តែចង្អៀតទៅ។ កិច្ចប្រតិបត្តិការរបស់ប៉ូលិស ក្នុងការចាប់ខ្លួន ការឃុំឃាំង និងបទចោទប្រកាន់ ត្រូវបានធ្វើឡើងដើម្បី បំភ័យនិងដាក់ពិន័យភាគីដែលទន់ខ្សោយជាងនៅក្នុងជម្លោះដីធ្លី ឬចំពោះអ្នកដែលប្រឆាំងនឹងគំរោង អភិវឌ្ឍន៍ ជាជាងផលប្រយោជន៍នៃអំពើយុត្តិធម៌ពិតៗ។

របាយការណ៍សង្ខេបនេះបង្ហាញនូវបរិបទ និងផ្តល់ជាឧទាហរណ៍នៃការរំលោភសិទ្ធិរបស់ អ្នកការពារសិទ្ធិមនុស្ស ដែលធ្វើការលើកកំពស់សិទ្ធិដីធ្លីនិងធ្វើការប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ក្នុងប្រទេសកម្ពុជា រវាងឆ្នាំ២០០៦-២០០៧ ហើយអត្ថបទនេះផ្អែកលើការចុះស្រាវជ្រាវដល់មូលដ្ឋាន របស់អង្គការលើកលែងទោសអន្តរជាតិ ដែលបានធ្វើឡើងក្នុងខែមីនា២០០៨។ ការវាយប្រហារទៅ លើសកម្មជនបែបនេះ គឺរំលោភបញ្ញត្តិច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលធានាសិទ្ធិសេរីភាពបញ្ចេញមតិ សិទ្ធិធ្វើសមាគម សិទ្ធិចូលរួមប្រជុំ និងសិទ្ធិចូលរួមក្នុងជីវភាពសាធារណៈ។ ពួកគេប្រឆាំងទៅនឹងសេចក្តី ប្រកាសរបស់សហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស[៤] ដែលឆ្លុះបញ្ចាំងនិងចែងលំអិតអំពីសិទ្ធិទាំង នេះដោយផ្តោតជាពិសេសលើអ្នកការពារសិទ្ធិមនុស្ស។ ក្នុងករណីជាច្រើន សិទ្ធិផ្សេងៗទៀតរបស់ អ្នកការពារសិទ្ធិមនុស្សត្រូវគេបានរំលោភ រួមមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងរួចផុត ពីការចាប់ខ្លួន និង ឃុំឃាំងតាមទំនើងចិត្ត។[៥]

## តើអ្នកការពារសិទ្ធិមនុស្សជានរណា?

អ្នកណាម្នាក់ដោយមិនគិតពីមុខងាររបស់ខ្លួន អាចជាអ្នកការពារសិទ្ធិមនុស្ស: ការសំគាល់ពួកគេ ជាអ្នកការពារសិទ្ធិមនុស្សជាបឋមគឺពួកគេធ្វើអ្វីដែលមិនមែនជាអាជីពរបស់ខ្លួន។ អ្នកការពារសិទ្ធិមនុស្ស ខ្លះគឺជា សកម្មជនសិទ្ធិមនុស្សវិជ្ជាជីវៈ ជាអ្នកច្បាប់ដែលធ្វើការអំពីករណីសិទ្ធិមនុស្ស អ្នកកាសែត សហជីពកម្មករ ឬមន្ត្រីអភិវឌ្ឍន៍។ ក៏ប៉ុន្តែប៉ូលិសម្នាក់ ឬតារាល្បីឈ្មោះម្នាក់ដែលមានសកម្មភាពលើក កំពស់ការគោរពសិទ្ធិមនុស្សក៏អាចជាអ្នកកាពារសិទ្ធិមនុស្សផងដែរ។

---

[៤] សេចក្តីថ្លែងការស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គល ក្រុមនិងអង្គការសង្គម ដើម្បីលើកកំពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី៨ មីនា ១៩៩៩

[៥] មាត្រា១៤និងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

អ្នកកាពារសិទ្ធិមនុស្សអាចធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់ ឬចូលរួមជាមួយអ្នកផ្សេងទៀតទៅតាមសមត្ថភាពផ្ទាល់ខ្លួនឬប្រកបដោយវិជ្ជាជីវៈ។ មានមនុស្សជាច្រើនការពារសិទ្ធិមនុស្សនៅពេលកំពុងបំពេញការងាររបស់ខ្លួន ចំណែកអ្នកផ្សេងទៀតក្លាយជាអ្នកកាពារសិទ្ធិមនុស្សដោយសារសកម្មភាពបុគ្គលផ្ទាល់ខ្លួន ឬជំហរ ដែលពួកគេប្រកាន់យកដើម្បីលើកកំពស់សិទ្ធិមនុស្ស។

ជារួមអ្នកកាពារសិទ្ធិមនុស្សមានលក្ខណៈសម្បត្តិជាច្រើន។ ពួកគេទាំងអស់គ្នា :

- លើកកំពស់គោលការណ៍ជាសកលជាមូលដ្ឋាន : នោះគឺមនុស្សជាតិទាំងអស់មានសិទ្ធិនិងសេចក្តីថ្លៃថ្នូរស្មើៗគ្នា ដោយមិនគិតពីជេនឌ័ ពូជសាសន៍ ជនជាតិដើម ឬមុខងារដទៃទៀតឡើយ។
- ប្តេជ្ញាធ្វើឱ្យសម្រេចបាននូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ
- គោរពសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ ទៅតាមសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ

សកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សត្រូវតែប្រកបដោយសន្តិវិធី ដើម្បីអនុវត្តទៅតាមសេចក្តីប្រកាសស្តីអំពីអ្នកការពារសិទ្ធិមនុស្ស ហើយត្រូវចូលក្នុងពាក្យដែលប្រើប្រាស់ដោយអង្គការ លើកលែងទោសអន្តរជាតិ។

សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សនិងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាបានផ្តល់បច្ចាប័ន មានអានុភាពអនុវត្តផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជា តាមរយៈមាត្រា៣១នៃច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣នៃប្រទេសកម្ពុជា។[៦] រដ្ឋធម្មនុញ្ញដែលមានចែងយ៉ាងច្បាស់លាស់ក៏បានការពារសិទ្ធិប្រជាជនកម្ពុជាគ្រប់រូបក្នុងការចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (មាត្រា៣៥) និងសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ (មាត្រា៤១)។

មានបុគ្គលនិងក្រុមផ្សេងៗកំពុងតែពាក់ព័ន្ធក្នុងវិស័យដែលពួកគេទទួលផលប៉ះពាល់ដោយផ្ទាល់ពីការការពារសិទ្ធិមនុស្សដែលទាក់ទងទៅនឹងការបណ្តេញចេញដោយបង្ខំ ហើយអង្គការលើកលែងទោសអន្តរជាតិ ចាត់ទុកពួកគេជាអ្នកការពារសិទ្ធិមនុស្ស។ ក្នុងចំណោមអ្នកទាំងនេះគឺជាអ្នកតំណាង សហគមន៍ផ្លូវការនិង មិនផ្លូវការ ដែលការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ សិទ្ធិទទួលបានសុខភាព និង សិទ្ធិចងក្រង

---

[៦] "មាត្រា៣១: ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។"

សមាគមដែលពួកគេរស់នៅ។ អ្នកដទៃទៀតរួមមានមេធាវីដែលធ្វើការក្នុងអង្គការជំនួយផ្នែកច្បាប់ដែលជាអ្នកទទួលកាន់រឿងក្តី ដើម្បីផ្តល់ការគាំទ្រដល់សហគមន៍ដែលប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំ មន្ត្រីអង្គការក្រៅរដ្ឋាភិបាលដែលកំពុងបង្កើនការយល់ដឹងអំពីសិទ្ធិដីធ្លី ឬជាអ្នកសង្កេតការករណីជម្លោះដីធ្លី និងអ្នកកាសែតដែលរាយការណ៍ពីរឿងដែលពាក់ព័ន្ធទាំងនោះ។

## សេរីភាពសំរាប់ការការពារសិទ្ធិមនុស្សកាន់តែចង្អៀតទៅ

ហ៊ីណា ជីឡានី តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកលើអ្នកការពារសិទ្ធិមនុស្ស(២000-២00៨) បានមានប្រសាសន៍ក្នុងឆ្នាំ២00៧ថា:-

"...*ការក្បៀបសង្កត់ទៅលើអ្នកការពារសិទ្ធិមនុស្ស ជាធម្មតាគឺជាសនទស្សន៍បង្ហាញនូវកង្វះខាត ការគោរពសិទ្ធិមនុស្ស យ៉ាងធំទូលាយនៅក្នុងរដ្ឋមួយ ហើយវាសមមាត្រផ្ទាល់ទៅនឹងស្ថាភាពដ៏ធំទូលាយនេះ*"

## អ្នកតំណាងសហគមន៍ប្រឈមនឹងគ្រោះថ្នាក់

នៅខ្សែជួរមុខនៃការការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិដទៃទៀតដែលទាក់ទងទៅនឹងដីធ្លីនិងលំនៅដ្ឋាន គឺជាបុគ្គលនិងក្រុមដែលធ្វើជាតំណាងអោយសហគមន៍ជាផ្លូវការឬមិនផ្លូវការដែលពួកគេកំពុងរស់នៅ។ អ្នកតំណាងសហគមន៍នៅទូទាំងប្រទេសទាំងនៅក្នុងតំបន់ជនបទនិងទីក្រុង បាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិអំពីវិធីនៃការចាប់ខ្លួន ការគំរាមកំហែងដោយ វិធានការផ្លូវច្បាប់ រួមមានការកាត់ទោស ដែលជាឧបសគ្គមួយកើតឡើងក្នុងចំណោមឧបសគ្គដ៏ធ្ងន់ធ្ងរបំផុតចំពោះសកម្មភាពរបស់ពួកគេ។[៧]

## ខេត្តបាត់ដំបង: ការចាប់ខ្លួនតាមទំនើងចិត្តនិងការកាត់ទោសដោយអយុត្តិធម៌

"*គេដាក់ច្រវាក់ខ្ញុំ ហើយដាក់ក្នុងបន្ទប់ងងឹតនៅក្នុងគុកអស់មួយអាទិត្យ។ ខ្ញុំវេទនាខ្លាំងណាស់ ហើយគេមិនអោយងូតទឹក។ មួយអាទិត្យក្រោយមក គេដោះច្រវាក់ចេញពីជើងរបស់ខ្ញុំ។*

[៧] បទសម្ភាសន៍និងកិច្ចប្រជុំជាមួយតំណាងជាង៣0សហគមន៍ដែលមានជម្លោះដីធ្លី ដោយប្រឈមនឹងការបណ្តេញចេញ ឬជាជនរងគ្រោះពីការបណ្តេញ ចេញដោយបង្ខំ ក្នុងខែកុម្ភៈនិងខែមីនា ២00៨

*វាជាច្រវាក់សម្រាប់ចងដំរី។ ពេលពួកគេដោះច្រវាក់ចេញ គេអោយខ្ញុំនៅខាងក្រៅកណ្តាលពន្លឺថ្ងៃ ហើយពួកគេបានសុំទោសខ្ញុំ។ ពួកគេបាន និយាយថាពួកគេធ្វើខុសដោយបានដាក់ទណ្ឌកម្មខុសមនុស្ស"*

ឈា នី ដែលជាមេដឹកនាំក្រៅផ្លូវការនៃភូមិបឹងប្រាំក្នុងស្រុកបវេល ខេត្តបាត់ដំបង ត្រូវបានចាប់ខ្លួន នៅថ្ងៃទី ០១ សីហា ២០០៦ លើរឿងជម្លោះដីធ្លីដ៏រាំរៃមួយ ជាមួយរដ្ឋអំណាចមូលដ្ឋាន ពួកឈ្មួញ និងយោធាដែលមានបុណ្យសក្តិខ្ពស់ៗ។

កម្លាំងប៉ូលិស កងរាជអាវុធហត្ថ និងទាហានជាង១០០នាក់បានមកចាប់ ឈា នី ដោយគ្មានដីកាចាប់ខ្លួនឡើយ។ អ្នកភូមិជាច្រើនរយនាក់រួមទាំងប្រពន្ធរបស់គាត់ផង បានធ្វើការរារាំងដើម្បីការពារ ឈា នី ពីការចាប់ខ្លួន។ បន្ទាប់ពីកម្លាំងសន្តិសុខ បានបាញ់ជាច្រើនគ្រាប់ឡើងទៅលើ ហើយបានវាយអ្នកភូមិជាច្រើននាក់ ការរារាំងបានបញ្ចប់ ហើយកម្លាំងសន្តិសុខបានចាប់ខ្លួន ឈា នី និងបានឃុំខ្លួនគាត់ក្នុងខេត្តបាត់ដំបង។ រយៈពេលបីខែក្រោយមក គេបានផ្ទេរគាត់មករាជធានីភ្នំពេញ ជាទីកន្លែងដំបូងបង្អស់ដែលគេឃុំគាត់អោយនៅឯកោ និងដោយត្រូវបានគេដាក់ខ្នោះជើង។ ជាថ្មីម្តងទៀត តុលាការខេត្តបាត់ដំបងមិនបានខ្វល់ នឹងសំណើររបស់ទីប្រឹក្សាច្បាប់របស់ ឈា នី ដោយទាមទារសុំអោយបញ្ជូនរូបគាត់ទៅកាត់ទោសនៅបាត់ដំបង។ នៅខែកុម្ភៈ ២០០៧ ទើបតុលាការខេត្តបាត់ដំបងបានកាត់ទោស ឈា នី អោយជាប់ទោស *ដោយកំបាំងមុខ*។




*ឈា នី បានជាប់ក្នុងពន្ធនាគាររយៈពេល១៦ខែ ដោយសារសកម្មភាពរបស់គាត់*

នេះគឺជាការរំលោភយ៉ាងច្បាស់ទៅលើសិទ្ធិទទួលបានការវិនិច្ឆ័យទោសដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ។ មាត្រា១២(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិង សិទ្ធិនយោបាយ

ដែលប្រទេសកម្ពុជាជារដ្ឋភាគីចែងថា: "ជនគ្រប់ៗរូបដែលត្រូវបានចោទប្រកាន់ ពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិ...ទទួលបានការវិនិច្ឆ័យទោសដោយមានវត្តមានរបស់ខ្លួន" ។ ចាប់តាំងពី ឈា នី ស្ថិតក្នុងការឃុំខ្លួនរបស់ប៉ូលិសមក ពុំមានការបង្ហាញយុត្តិកម្មកែតម្រូវកំហុសដើម្បីនាំរូបគាត់ទៅកាន់តុលាការទេ។ លើសពីនេះទៀតពុំមាន ភស្តុតាងណាបញ្ជាក់លើបទចោទ "ការរំលោភលើកម្មសិទ្ធិ "[៨] ជាបទចោទប្រកាន់ ដែលមិនចាត់ទុកជាបានការនូវការពិតនៃបញ្ហាដែលជាដើមហេតុជម្លោះ- មិនបានបញ្ជាក់អោយច្បាស់ថា ដីនោះ ជាកម្មសិទ្ធិរបស់រដ្ឋ ឬបុគ្គលឯកជនឡើយ។ បន្ទាប់ពីប្តឹងឧទ្ធរណ៍ជោគជ័យដោយប្រឆាំងនឹងការ កាត់ទោស*កំបាំងមុខ* ឈា នី ត្រូវបានកាត់ទោសសារជាថ្មីរយៈពេលបីខែក្រោយមក ដែលពេលនោះ ត្រូវបានអនុញ្ញាតឱ្យមានវត្តមានជាមួយមេធាវីរបស់គាត់។ គាត់ត្រូវបានរកឃើញថាមានទោសជាថ្មីម្តងទៀត ទោះបីនៅក្នុងសាលក្រម ការចោទប្រកាន់បានផ្លាស់ប្តូរពី "ទ្រព្យឯកជន" ទៅ "ទ្រព្យសាធារណៈ" ក៏ដោយ។ គាត់ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល៩ខែ ដែលជារយៈពេលគាត់បានទទួលទោសរួចហើយ។ ដោយរង់ចាំឧទ្ធរណ៍របស់អយ្យាការ ឈា នី បានជាប់ក្នុងគុករហូតដល់ខែធ្នូ ឆ្នាំ២០០៧ នៅពេលដែលគាត់ត្រូវបាន ដោះលែងដោយមានការធានា។ ការប្តឹងឧទរណ៍នៅតែកំពុងរង់ចាំសវនាការ។

អ្នកភូមិបឹងប្រាំជាច្រើនបានរស់នៅក្នុងភូមិនេះតាំងពីឆ្នាំ១៩៩៧ ពេលដែលពួកគេបានប្រកាសថា រដ្ឋអំណាចបានអោយដីទៅពួកគេ ដែលជាអតីតគ្រួសារខ្មែរក្រហមដែលបានធ្វើសមាហរណកម្មដើម្បីដាំដំណាំកសិកម្ម។ ជម្លោះបានចាប់ផ្តើម ពេលមន្ត្រីយោធាមួយចំនួនបានប្រកាសថាជាកម្មសិទ្ធិរបស់ខ្លួន ហើយបានលក់បន្តទៅអោយឈ្មួញឯកជន។ បន្ទាប់មក ឈា នី និងអ្នកតំណាងឯទៀតបានចាត់ចែងបង្កើតជាសហគមន៍ ដើម្បីធ្វើញត្តិទៅកាន់រដ្ឋាភិបាល ដើម្បីបដិសេធនឹងការប្រកាសនេះ ហើយស្វែងរក "សម្បទានដីសង្គមកិច្ច" ដែលជាយន្តការមួយសម្រាប់បែងចែកដីធ្លីដល់អ្នកដែលគ្មានដី ចែងក្នុងច្បាប់

---

[៨] គេបានរាយការណ៍មកថាជា នីត្រូវបានចោទប្រកាន់ពីបទល្មើស រួមមានក្នុងមាត្រា២៥៣ ( ជំពូក១៩ នៃច្បាប់ភូមិបាល២០០១ស្តីពីទោសប្បញ្ញត្តិនៃ ច្បាប់ ដែលចែងថា: - *"ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលវត្ថុដោយសុច្ចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានប្រាំសែនរៀល ដល់ ម្ភៃប្រាំលានរៀល ឬដាក់ពន្ធនាគារពី៦ ( ប្រាំមួយ) ខែ ដល់២ ( ពីរ) ឆ្នាំ ដោយពុំទាន់គិត បញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស ។ បន្ថែមលើទោសខាងលើ អ្នកប្រព្រឹត្តអំពើហិង្សាត្រូវទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ ដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន ។ បើអំពើហិង្សាខាងលើត្រូវបានបញ្ជាពីជនដទៃទៀតក្រៅពីអ្នកបង្ក ហើយជននោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានេះក៏ត្រូវទទួលការផ្តន្ទាទោសដូច អ្នកប្រព្រឹត្តអំពើហិង្សាផ្ទាល់ដែរ ។"* ពុំមានភស្តុតាងណារកឃើញបង្ហាញថា ជា នីបានប្រព្រឹត្តអំពើហិង្សាទេ។

ភូមិបាលឆ្នាំ២០០១ ដោយអនុញ្ញាតដល់រដ្ឋាភិបាល អាចបែងចែកដីរដ្ឋអោយប្រជាជនក្រីក្រនិងគ្មានដីធ្លីសម្រាប់ប្រើប្រាស់ជាលំនៅដ្ឋានឬដាំដំណាំកសិកម្ម។[៩]

អ្នកតំណាងសហគមន៍ពីរនាក់ទៀតដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី១សីហា២០០៦ជាមួយ ឈា នី ដោយបានព្យាយាមការពារគាត់ ត្រូវបានដោះលែងអោយនៅក្រៅឃុំដោយមានការធានានៅថ្ងៃបន្ទាប់។ ខណៈដែលពីរនាក់ផ្សេងទៀតបានគេចខ្លួនហើយនៅលាក់ខ្លួនតាំងពីពេលនោះមក។ អ្នកទាំងពីរនាក់នេះត្រូវបានកាត់អោយជាប់ទោសដោយកំបាំងមុខផងដែរដោយជាប់ពន្ធនាគារមួយឆ្នាំនិងសងសំណង ដែលបានសំរេចក្នុងពេលសវនាការ*កំបាំងមុខ*លើកដំបូងរបស់ ឈា នី។ មួយខែក្រោយមក បុរសពីរនាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន គឺ ហែម ឡាក់ និង មូ សាប។ ពួកគេម្នាក់ៗត្រូវបាន កាត់ទោសអោយជាប់ពន្ធនាគារ៦ខែ ហើយត្រូវបានដោះលែងពីពន្ធនាគារនៅខែឧសភាឆ្នាំ២០០៧ បន្ទាប់ពីបានទទួលទោសរួចមក។

## លំនាំនៃការចាប់ខ្លួននិងការវិនិច្ឆ័យដោយអយុត្តិធម៌

ឈា នី និងអ្នកដឹកនាំភូមិបឹងប្រាំងទៀត មិនត្រឹមតែជាអ្នកតំណាងសហគមន៍ត្រូវបានចាប់ខ្លួនទេ ដែលទំនងជាការប៉ុនប៉ងបំបិទមាត់ពួកគេនិងបញ្ឈប់សកម្មភាពតវ៉ាដោយសន្តិវិធីរបស់ពួកគេ។ អង្គការសិទ្ធិមនុស្សលីកាដូបានផ្តល់ព័ត៌មានអំពីការចាប់ខ្លួនអ្នកតំណាងសហគមន៍ចំនួន៥០ករណីនៅទូទាំងប្រទេស ចាប់ពីខែ មករា ២០០៦ ទាំងនៅក្នុងតំបន់ទីក្រុងនិងតំបន់ជនបទ។[១០]

"ការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដោយខុសច្បាប់" និង "ការរំលោភលើទ្រព្យសម្បត្តិឯកជន" គឺជាមូលដ្ឋានដូចៗគ្នាដែលត្រូវបានប្រើប្រាស់សម្រាប់ចាប់អ្នកតំណាងសហគមន៍ ដែលបទចោទប្រកាន់ទាំងនេះ ត្រូវបានគេយកមកប្រើដូចៗគ្នាទាំងអស់។ ជាទម្លាប់ព្រះរាជអាជ្ញាច្រានចោលមិនយកមកពិចារណាដើម្បីបញ្ជាក់ បំភ្លឺថាតើកម្មសិទ្ធិដីស្របច្បាប់ឬអត់ មុនធ្វើការចោទប្រកាន់។ ផ្ទុយទៅវិញពួកគាត់បានចោទប្រកាន់អ្នកតំណាងសហគមន៍ចំពោះហេតុការណ៍ ដូចជា មានការដកបង្គោលរបងរបស់ខ្លួនចេញពីដី ដែលពួកគាត់ថាជាកម្មសិទ្ធិរបស់ខ្លួន ដើម្បីធ្វើតវ៉ាដោយសន្តិវិធីឬដើម្បីលើកបដាតវ៉ា

[៩] ដូចបានលំអិតក្នុងអនុក្រឹត្យស្តីអំពីសម្បទានដីសង្គមកិច្ច លេខ១៩អ.ន.ក្រ.ប.ក ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣។

[១០] អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
: *ការវាយប្រហារនិងការគំរាមកំហែងអ្នកកាពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជានៅឆ្នាំ២០០៦*—ខែធ្នូ ២០០៦ —
*ការវាយប្រហារនិងការគំរាមកំហែងអ្នកការពារសិទ្ធិមនុស្សនៅឆ្នាំ២០០៧*— ខែកញ្ញា ឆ្នាំ២០០៨

នៅលើដីដែលមានជម្លោះ ជាបទចោទប្រកាន់ដែលសមាជិកសហគមន៍ អ្នកឃ្លាំមើលសិទ្ធិមនុស្ស និងអ្នកសង្កេតការផ្សេងទៀតបានចាត់ទុកថា មិនត្រឹមត្រូវនិងគ្មានមូលដ្ឋាន។

ក្នុងករណីផ្សេងទៀត តុលាការនិងព្រះរាជអាជ្ញាបានចោទប្រកាន់អ្នកតំណាងពីបទល្មើសផ្សេងៗ រួមមាន ប្លន់ បង្ករបួសស្នាម កាប់ឆ្ការព្រៃខុសច្បាប់និងបរិហាកេរ្តិ៍ នេះជាឧទាហរណ៍ ដែលព្រះរាជអាជ្ញាបានដាក់បទចោទប្រកាន់ផ្អែកលើមូលដ្ឋានទាំងនេះ។ អង្គការលើកលែងទោសអន្តរជាតិដឹងពីរករណី ដែលអ្នកតំណាងសហគមន៍ត្រូវបានចោទប្រកាន់ពីអំពើប្លន់[១១] នៅពេលពួកគាត់ប្រមូលផលស្រូវលើវាលស្រែដែលពួកគាត់បានធ្វើនៅលើដីដែលមានជម្លោះនោះ។ កាលៈទេសៈទាំងអស់នេះ នៅពេលអ្នកតំណាងពីររូបរបស់ប្រជាជន២២០ គ្រួសារនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យត្រូវបាន វិនិច្ឆ័យទោសពីបទប្លន់[១២] ក្នុងខែមករាឆ្នាំ២០០៧ ហើយក្នុងខែឧសភាឆ្នាំ២០០៧ អ្នកតំណាងសហគមន៍ នៅក្នុងស្រុកពាមជរនៃខេត្តព្រៃវែង ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ដោយបទល្មើសដូចគ្នា។[១៣]

ក្នុងខែសីហាឆ្នាំ២០០៧ តុលាការខេត្តសៀមរាប បានកោះហៅបុរសពីររូបដែលជាតំណាងមិនផ្លូវការរបស់ប្រជាជន១០០គ្រួសារ ដែលបានពាក់ព័ន្ធក្នុងជម្លោះដីនៅស្រុកពួក ខេត្តសៀមរាប ដោយបានចាប់ខ្លួនពួកគេនៅ ពេលទៅដល់តុលាការ បន្ទាប់ពីលោកព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពួកគេពីបទមានកំហុសធ្វើអោយខូចខាតទ្រព្យសម្បត្តិ។ យោងតាមមន្ត្រីសិទ្ធិមនុស្សដែលបានសង្កេតការលើករណីនេះ បទចោទប្រកាន់គឺទាក់ទងទៅនឹងក្រុមគ្រួសារដែលបានភ្ជួរដីដែលពួកគាត់បានប្រកាសអះអាងថាជាកម្មសិទ្ធិស្របច្បាប់របស់ពួកគាត់។ បន្ទាប់ពីអ្នកភូមិប្រមូលគ្នាមកតវ៉ានៅមុខតុលាការខេត្តសៀមរាប អ្នកទាំងពីរត្រូវបានដោះលែងប៉ុន្មានថ្ងៃក្រោយមក ក៏ប៉ុន្តែគេបានជឿជាក់ថាបទចោទប្រកាន់នៅព្យួរទុកនៅឡើយ។

នៅភូមិដីក្រហមឯភ្នំពេញនេះវិញ ប៉ូលិសបានចាប់ខ្លួនរស់ ពៅ ជាអ្នកតំណាងសហគមន៍ស្ត្រីភេទនៅក្នុងខែកញ្ញាឆ្នាំ២០០៧ ហើយតុលាការក្រុងភ្នំពេញបានកាត់ទោសគាត់អោយជាប់ទោសក្នុងខែមករា ២០០៨ ពីបទ"បង្ករបួសស្នាម"ដល់កម្មកររបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ដោយកាត់អោយជាប់ពន្ធនាគារ

---

[១១] មាត្រា៣៤នៃច្បាប់អ៊ុនតាក់ចែងថាអំពើប្លន់គឺជាការលួចឬប៉ុនប៉ងនឹងលួចដោយមានស្ថានទម្ងន់ទោសដូចជាប្រើហិង្សាឬប្រព្រឹត្តឡើងដោយមានគ្នាច្រើន។

[១២] ការរំលោភយកដី អំពើពុករលួយ និងការគ្មានច្បាប់: មជ្ឈមណ្ឌលធនធានច្បាប់អាស៊ី ថ្ងៃទី៤ មីនា ២០០៧

[១៣] ចំណោមពួកគាត់ម្នាក់ត្រូវបានដោះលែងដោយមានការធានា ឯម្នាក់ទៀតនៅក្នុងការឃុំឃាំងរង់ចាំការកាត់ទោស។ ត្រឹមខែកញ្ញា ២០០៨ តុលាការពុំបានកំណត់ថ្ងៃសម្រាប់ការកាត់ទោសទេ។ អង្គការ លីកាដូ :-
*ការវាយប្រហារនិងការគំរាមកំហែងលើអ្នកការពារសិទ្ធិមនុស្សក្នុងប្រទេស កម្ពុជានៅឆ្នាំ២០០៧*— ខែកញ្ញាឆ្នាំ២០០៨

រយៈពេលប្រាំមួយខែ និងព្យួរទោស១៨ខែថែមទៀត។[១៤] បទចោទពីការបង្ករបួសស្នាមត្រូវបានធ្វើឡើង នៅក្នុងបរិបទនៃជម្លោះដីដែលកំពុងបន្តរវាងសហគមន៍មូលដ្ឋាននិងក្រុមហ៊ុន។ សាក្សីឃើញហេតុការណ៍ ដែលបណ្តាលអោយគាត់ជាប់ពន្ធនាគារនោះ បានរាយការណ៍ថាពុំបានឃើញមានអំពើហិង្សាដែលបង្កឡើងដោយ រស់ ពៅ ឡើយ ហើយអ្នកសង្កេតការបានបញ្ជាក់ថាអំឡុងសវនាការនោះ ការវិនិច្ឆ័យទោសខកខានមិនបានបង្ហាញអោយឃើញថារូបគាត់បានធ្វើអោយកម្មករក្រុមហ៊ុនណាម្នាក់មានរបួសស្នាមឡើយ។

## ការគំរាមចាប់ខ្លួននិងការឃុំឃាំង

ពីង យក់ហៀប នាយិកាអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ស្តីអំពីជម្លោះដីពាក់ព័ន្ធនឹងជនជាតិដើមចាយ៉ាយក្នុងខេត្តរតនគិរីបានមានប្រសាសន៍ថា :-

*"គ្មានឧទាហរណ៍ណាច្បាស់ជាងនេះនៅប្រទេសកម្ពុជា ដែលអ្នកមាននិងអ្នកមានអំណាចទាញយកផលប្រយោជន៍ពីប្រជាពលរដ្ឋក្រីក្រ។ ហើយក៏មិនមានឱកាសណាដូចនេះដែរដែលប្រព័ន្ធយុត្តិធម៌ដើរតួនាទីចុងក្រោយយ៉ាងសំខាន់ ក្នុងការអនុវត្តច្បាប់ និងការពារសិទ្ធិ របស់ជនជាតិដើមភាគតិចប្រឆាំងនឹងការរំលោភអំណាច"។*[១៥]

ក្នុងខេត្តរតនៈគិរីនៅភាគឦសាន មានអ្នកតំណាង១៨នាក់ពីភូមិ គង យុ និងភូមិ គង ធំ របស់ជនជាតិដើមភាគតិចចារ៉ាយនៃប្រទេសកម្ពុជា បានរងការប្តឹងពីបទព្រហ្មទណ្ឌក្នុងខែមិថុនា ឆ្នាំ ២០០៧ ដែលចោទប្រកាន់ពួកគាត់ពីបទគែបន្លំនិងបរិហាកេរ្តិ៍។[១៦] នៅពីក្រោយការចោទប្រកាន់គឺជាអ្នកជំនួញស្ត្រីម្នាក់គឺអ្នកស្រី គាត កុលណៃ ដែលជាប្អូនស្រីបង្កើតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយជាភរិយារបស់មន្ត្រីជាន់ខ្ពស់ម្នាក់នៅក្នុងក្រសួងរៀបចំដែនដី ដោយបានប្រកាសថា

---

១៤ *របាយការណ៍សកម្មភាពរយៈពេល៦ខែ អង្គការលីកាដូ— ជំរឿននិងការការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា— ខែមករា-មិថុនា ២០០៨- ខែសីហា ២០០៨*

១៥ *សេចក្តីថ្លែងការណ៍សារព័ត៌មានរួម* ថ្ងៃទី២៣ មករា ២០០៧ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា វេទិកា អង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា សហគមន៍ព្រៃឈើអន្តរជាតិ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ អង្គការជំនួយច្បាប់កម្ពុជា អង្គការពលកម្ម អន្តរជាតិ អង្គការគាំពារកុលសម្ព័ន្ធ និងជនជាតិភាគតិចកម្ពុជា

១៦ ព័ត៌មានបន្ថែមស្តីពីការបណ្តេញចេញដោយបង្ខំនិងអំពីជនជាតិភាគតិចនៅកម្ពុជា សូមមើលរបាយការណ៍អង្គការលើកលែងទោសអន្តរជាតិករណីអំពាវនាវ : *កម្ពុជា: មិនរវល់ដល់សិទ្ធិជនជាតិភាគតិច*— អង្គការលើកលែងទោសអន្តរជាតិ ខែមិថុនា ឆ្នាំ២០០៨

បានទិញដី ៤៥០ហិកតាពីអ្នកភូមិ សម្រាប់ដាំចំការកៅស៊ូ។ ក្រុមប្រជាជនដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងពីរនេះ ដែលក្នុងនោះមានបទតែបន្ទំអាចទទួលទោសជាប់ឃុំឃាំងរហូតរយៈពេលប្រាំឆ្នាំ ពួកគេគឺជាតំណាង អោយសហគមន៍ដែលស្ថិតក្នុងជម្លោះដីនោះ ដែលបានកើតឡើងក្នុងឆ្នាំ២០០៤ ហើយបានដកហូតពីពួកគាត់ នូវដីកម្មសិទ្ធិរួមរបស់ ជនជាតិភាគតិចហើយទំនងជាមានការបណ្ដេញចេញដោយបង្ខំផងដែរ។[១៧] រហូតមកដល់ពេលនេះ ដីចំនួនប្រមាណ ២៧០ហិកតា ត្រូវបានកាប់ឆ្ការសម្រាប់ដាំកៅស៊ូ។ ដីដែលនៅសល់១៨០ ហិកតាទៀត រួមមានដីកសិកម្ម ព្រមទាំងដីព្រៃ គឺជាតំបន់វប្បធម៌និងសាសនា ដូចជាព្រៃអ្នកតានិងជាទីបញ្ចុះសពរបស់ភូមិទាំងពីរ។

បន្ទាប់ពីពាក្យបណ្ដឹងបានដល់តុលាការខេត្តរតនៈគិរីភ្លាម ព្រះរាជអាជ្ញាខេត្តបានកោះហៅអ្នកតំណាងទាំងនោះដើម្បីសាកសួរ ដោយបើកការស៊ើបអង្កេតបទល្មើស ព្រមជាមួយនឹងលេចចេញសញ្ញាប្រឈមនឹងការចាប់ខ្លួនទៀតផង។ អ្នកតំណាងម្នាក់បាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិអំពីការគំរាមកំហែង ដែលពួកគាត់បានទទួលដោយផ្ទាល់ពីមន្ត្រីប្រតិបត្តច្បាប់ជាន់ខ្ពស់ម្នាក់ដែលមន្ត្រីរូបនោះមានការទាក់ទងទៅនឹងករណីនេះ ៈ-

*"លោកនាយប៉ូលិសស្រុកបានប្រាប់យើងថាៈ-បើអ្នកឯងនៅតែតវ៉ាទៀត ខ្ញុំនឹងចាប់អ្នកឯងដាក់គុក។ ហើយប្រសិនបើអ្នកឯង កាប់ដើមឈើអ្នកដទៃ អ្នកឯងត្រូវជាប់គុក។"*

ដោយមិនបានកោះហៅអ្នកភូមិមកសាកសួរតាមផ្លូវច្បាប់ លោកព្រះរាជអាជ្ញាបានយកសេចក្ដីប្រកាស៤១ច្បាប់ដែលបានធ្វើដោយអ្នកភូមិ ដើម្បីយកមកធ្វើការស៊ើបអង្កេតពីបទព្រហ្មទណ្ឌក្នុងខែ កក្កដា ឆ្នាំ២០០៧ ដែលពាក្យនោះបានបញ្ជាក់ថាពួកគាត់បានសុខចិត្តលក់ដីជម្លោះនោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកភូមិស្ទើរតែទាំងអស់បាននិយាយក្រោយមកថា គេអោយពួកគាត់ផ្ដិតមេដៃក្នុងសេចក្ដីប្រកាសនោះ ដែលភាគច្រើនជាភាសាខ្មែរដែលពួកគាត់មិនយល់[១៨] ហើយពួកគាត់ត្រូវបានគំរាមកំហែង ដោយសហការីរបស់ គាត កុលណើ ដែលពួកគេមានវត្តមាននៅពេលនោះ ប្រសិនពួកគេប្រកែកមិនព្រមទទួលស្គាល់។ អ្នកភូមិមួយចំនួនទៀតដែលខ្លួនបានផ្ដល់សេចក្ដីប្រកាសនោះ មិនបានពាក់ព័ន្ធក្នុងជម្លោះដីនោះទេ ហើយខ្លួនបានសារភាពថាបានផ្ដល់សេចក្ដីប្រកាសនោះដើម្បីប្រាក់។ ក៏ប៉ុន្តែ អគ្គព្រះរាជ

---

[១៧] សេចក្ដីសន្និដ្ឋាននេះត្រូវបានប្រកែកដោយឆែ វិបុលដែលជាមេធាវីរបស់គាត កុលណើ។ គាត់បាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិថា គាត កុលណើគឺជាម្ចាស់ដីស្របច្បាប់ ហើយមាន "ឯកសារទាំងអស់ដើម្បីបញ្ជាក់"

[១៨] អ្នកភូមិភាគច្រើនដែលមានវ័យកណ្ដាល មិនចេះអានភាសាខ្មែរនិងនិយាយខ្មែរមិនច្បាស់។ សូមអានរបាយការណ៍វប្បធម៌ របស់បណ្ឌិតមាស នី ដែលបានដាក់ទៅតុលាការនៅថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ ទំព័រ១០។

អាជ្ញានៃសាលាឧទ្ធរណ៍បានស្តីបន្ទោសព្រះរាជអាជ្ញាតុលាការខេត្ត ហើយបានបញ្ជាគាត់អោយអនុវត្តទៅតាមច្បាប់ ក៏ប៉ុន្តែពុំដឹងថាតើវិធានការវិន័យ ត្រូវបានចាត់ការដោយអាជ្ញាធរយ៉ាងណានោះទេ។

ការបាត់បង់ដីបានចាប់ផ្តើមក្នុងឆ្នាំ២០០៤ នៅពេលមន្ត្រីមូលដ្ឋានបានធ្វើការប្រជុំជាច្រើនសារនៅក្នុងបរិយាកាសបំភិតបំភ័យ ដោយបានសុំអោយសហគមន៍យល់ព្រមលក់ដីសមូហភាពខ្លះរបស់ពួកគាត់ដោយ គំរាមថាបើមិនព្រមទេ រដ្ឋនឹងរឹបអូសយកដីនោះ។ ដោយស្ទាក់ស្ទើរចិត្ត សហគមន៍បានយល់ព្រមអោយដី៥០ ហិកតាទៅទាហានរំសាយពិការ ក្នុងនាមលោកនាយករដ្ឋមន្ត្រី ពីព្រោះពួកគាត់និយាយថាគេបានណែនាំពួកគាត់អោយធ្វើដូច្នេះ។ ក្រោយពីកិច្ចព្រមព្រៀងដោយផ្ទាល់មាត់មក ក្នុងខែកក្កដាឆ្នាំ២០០៤ មកមន្ត្រីពីថ្នាក់ឃុំ និងខេត្តបាននាំយកអាហារនិងគ្រឿងស្រវឹងអោយអ្នកភូមិ ដើម្បីរៀបចំពិធីបុណ្យមួយ។ នៅរាត្រីនោះមន្ត្រីបានធ្វើឯកសារជាភាសាខ្មែរដើម្បីអោយអ្នកភូមិផ្តិតមេដៃ។ អ្នកភូមិម្នាក់បាននិយាយប្រាប់អង្គការ លើកលែងទោសអន្តរជាតិថាៈ-

*"ពួកគេមិនបានពន្យល់ ឬអានឯកសារនោះទេ គឺគ្រាន់តែអោយពួកយើងផ្តិត មេដៃប៉ុណ្ណោះ"*

អ្នកតំណាងភូមិបាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិថា ក្រោយមកពួកគាត់បានដឹងថាការផ្តិតមេដៃនោះគឺបានយល់ព្រមថាសុខចិត្តប្រគល់ដីសហគមន៍ "រាប់រយហិកតា" ទៅអោយឈ្មួញកណ្តាលម្នាក់ ដែលក្រោយមកលក់ដីនោះបន្តទៅអោយសមាគមមួយដែលអ្នកស្រី គាត កុលណើ ជាប្រធានដើម្បីធ្វើជាចំការកៅស៊ូ។ សមាគមនេះមានឈ្មោះថា "សមាគមកសិករវឌ្ឍនៈ" ដែលបានចុះបញ្ជីឈ្មោះសមាគមជាមួយក្រសួងមហាផ្ទៃនៅថ្ងៃទី២៥ កុម្ភៈ ២០០៥ ដែលការចុះបញ្ជីនេះ កើតក្រោយពេលដែល គាត កុលណើ បានប្រកាសថាគាត់បានទិញដី។ អ្នកតំណាងភូមិម្នាក់បាននិយាយ ប្រាប់អង្គការលើកលែងទោសអន្តរជាតិថា កិច្ចសន្យាជាភាសាខ្មែរ បានចុះថ្ងៃទិញលក់ក្នុងឆ្នាំ២០០១ គឺរយៈពេលបីឆ្នាំមុន ហើយនិងមុនការអនុម័តច្បាប់ភូមិបាល។

*"ពួកគេបានហាមប្រាមយើងខ្ញុំមិនអោយប្រាប់ជនចំឡែកថាដីនេះបានលក់នៅក្នុងឆ្នាំ២០០១ទេ ប៉ុន្តែថាលក់ ក្នុងឆ្នាំ២០០៤"*។ ជាលទ្ធផល ការឈ្លូសឆាយដីបានកើតឡើង ហើយអ្នកភូមិបានធ្វើការតវ៉ា។

បណ្តឹងបទព្រហ្មទណ្ឌទំនងត្រូវបានធ្វើ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងរដ្ឋប្បវេណីដែលតំណាងសហគមន៍បានប្តឹង គាត កុលណើ កាលពី៦ខែមុន គឺនៅក្នុងខែមករាដើមឆ្នាំ២០០៧។ ពាក្យបណ្តឹងនេះប្រឆាំងនឹងសុពលភាព កិច្ចសន្យាលក់ទិញរវាង គាត កុលណើ និងអ្នកភូមិចារ៉ាយទាំងពីរភូមិ គឺភូមិគងយុ និងភូមិគងធំ។ យោងតាមអ្នកតំណាងភូមិ ឈ្មួញកណ្តាលនិងអាជ្ញាធរមូលដ្ឋានបានប្រើល្បិចកលបង្ខំ

បោកប្រាស់ និងយាយីពួកគាត់អោយយល់ព្រមលក់ដី ដែលមិនគិតដល់ច្បាប់ភូមិបាលឆ្នាំ២០០១។[១៩] បន្ថែមលើបណ្តឹងរដ្ឋប្បវេណីទៀតនោះ សហគមន៍បានដាក់ពាក្យបណ្តឹងបទព្រហ្មទណ្ឌទៅលោកព្រះរាជអាជ្ញាតុលាការខេត្តរតនៈគិរី ដោយចោទប្រកាន់ អ្នកស្រី គាត កុលណើ ថាបានយកដីរបស់ពួកគាត់ធ្វើជាកម្មសិទ្ធិដោយមិនស្របច្បាប់។ លោក ឆៃ វិបុល មេធាវីរបស់ គាត កុលណើ បានជំទាស់នឹងបទចោទប្រកាន់ទាំងពីរទៅលើកូនក្តីរបស់ខ្លួន។ គាត់បាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិថា ទោះបីច្បាប់ភូមិបាលការពារដីធ្លីជនជាតិដើមភាគតិចក៏ដោយ ក៏ការផ្ទេរដីនេះគឺធ្វើទៅតាមនីតិវិធីត្រឹមត្រូវតាមច្បាប់។ លោកឆៃ វិបុលបាននិយាយថា: "ពួកគាត់ចាំបាច់ត្រូវលក់ដី(មួយផ្នែក)ពីព្រោះពួកគាត់ពុំមានអាហារគ្រប់គ្រាន់" ដោយលោកបានប្រកាសអះអាងថាកូនក្តីរបស់លោកមានឯកសារដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជាក់ពីកម្មសិទ្ធិលើដីជម្លោះនោះ។

នៅថ្ងៃទី២៤ មេសា ២០០៨ ចៅក្រមជំនុំជម្រះបណ្តិត យ៉ា ណារិន ដែលជាប្រធានតុលាការខេត្តរតនៈគិរីនិងជាចៅក្រមម្នាក់នៅក្នុងតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទៅកន្លែងកើតហេតុធ្វើការស៊ើបអង្កេត។ អ្នកភូមិបានព្យាយាមនិយាយប្រាប់គាត់អំពីដំណើររឿងនៃព្រឹត្តិការណ៍ឆ្នាំ២០០៤។ នៅពេលអ្នកភូមិបានពន្យល់ថាអាជ្ញាធរមូលដ្ឋានបានប្រាប់ពួកគាត់ថាហ៊ុន សែន ត្រូវការដីសម្រាប់ទាហានពិការរបស់ខ្លួន លោកចៅក្រមបាននិយាយថា: *"អ្នកឯងមិនត្រូវនិយាយឈ្មោះលោកនាយករដ្ឋមន្ត្រីទេ ពីព្រោះការពាក់ព័ន្ធឈ្មោះរបស់គាត់ធ្វើអោយករណីនេះជារឿងនយោបាយ។ ករណីមុនៗ ខ្ញុំបានដាក់គុកអ្នកភូមិដែលបានធ្វើអោយករណីទៅជារឿងនយោបាយ។ តុលាការមិនពិចារណាករណីនេះទេ ប្រសិនបើពាក់ព័ន្ធរឿងនយោបាយ"*។[២០]

បួនឆ្នាំក្រោយ ករណីនៅមិនទាន់បានដោះស្រាយ។

ខណៈពេលនោះ តំណាងអ្នកភូមិបានប្រាប់អង្គការលើកលែងទោសអន្តរជាតិថាគ្រួសារទាំងអស់ក្នុងភូមិទាំងពីរដែលរងផលប៉ះពាល់នោះពួកគាត់ជួបការលំបាកនឹងជីវភាពខ្វះខាត បន្ទាប់ពីពួកគាត់

---

[១៩] មាត្រា២៣នៃច្បាប់ភូមិបាល:"សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមាជិក ទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណីនិងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាម ក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនទ្រព្យរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។

[២០] កាយវិការរបស់លោកចៅក្រមជំនុំជម្រះនៅនឹងទីកន្លែងស៊ើបអង្កេតត្រូវបានថតដោយម៉ាស៊ីនថតវីដេអូ

បាត់បង់ដីសហគមន៍។ ជម្លោះដីបានធ្វើអោយអ្នកភូមិបាត់បង់ពេលវេលា ប្រាក់កាសនិងធនធានផ្សេងៗទៀត។

អំពើហិង្សាការចាប់ខ្លួន និងការគំរាមកំហែង គឺជារឿងពិតចំពោះអ្នកតំណាងភូមិ ដែលពាក់ព័ន្ធក្នុងវិវាទដីធ្លីនិងការបណ្តេញចេញដោយបង្ខំ និងចំពោះអ្នកដែលគាំទ្រពួកគាត់។ ក្នុងឆ្នាំកន្លងទៅ គឺនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ នៅក្នុងការបណ្តេញចេញដ៏ហិង្សាបំផុតមួយ ប៉ូលិសបានបាញ់សម្លាប់លោកស្រី តឿន ឆេង អាយុ២៩ឆ្នាំ ជាប្រពន្ធរបស់អ្នកតំណាងភូមិម្នាក់និងជាម្តាយមានកូនបួននាក់ នៅក្នុងឃុំកន្ទួតខេត្តព្រះវិហារ នៅពេលកម្លាំងសន្តិសុខបានស្វែងចាប់ខ្លួនប្តីរបស់គាត់ ពីបទរំលោភលើកម្មសិទ្ធិសាធារណៈ ឬការរំលោភលើដី សាធារណៈ។ ប្តីរបស់គាត់ដែលប៉ុនប៉ង ការពារកម្មសិទ្ធិសហគមន៍ក្នុងនាមដែលគាត់ជាតំណាងឱ្យសហគមន៍ក្រៅផ្លូវការ ត្រូវបានចាប់ខ្លួនប៉ុន្មាន ម៉ោងក្រោយមក នៅពេលដែលកម្លាំងសន្តិសុខបានកំទេចបំផ្លាញភូមិ និងចាប់ខ្លួនអ្នកភូមិឯទៀត។ រូបគាត់ នឹងអ្នកភូមិប្រាំនាក់ទៀតត្រូវបានជាប់ឃុំជាមួយគ្នា ដោយរង់ចាំការកាត់ទោសនៅភ្នំពេញ។ អំឡុងពេលធ្វើរបាយការណ៍ នេះពុំមានការស៊ើបអង្កេតធ្វើឡើងទៅលើការសម្លាប់ លោកស្រី តឿន ឆេង ឡើយ។

ករណីនៅភូមិគងយុ បឹងប្រាំ និងករណីផ្សេងៗទៀតដែលបានលើកឡើងមកនេះ គឺបង្ហាញអោយឃើញ នូវលំនាំមួយដែលរដ្ឋអំណាចនិងមន្ត្រីប្រត្តិបត្តច្បាប់ បាននិងកំពុងដៅទៅលើអ្នកតំណាងសហគមន៍ដែលការពារសិទ្ធិមនុស្ស។ នៅក្នុងករណីទាំងអស់នេះ ពួកមន្ត្រីទាំងនោះបានសម្តែងយ៉ាងច្បាស់នូវការគាំទ្រចំពោះ បុគ្គល ឬក្រុមដែលមានអំណាចដែលផ្ទុយនឹងការធានាអោយមាន ការការពារសិទ្ធិមនុស្ស កុំអោយមានការរើសអើង និងធ្វើទៅតាមនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់នោះឡើយ។ លើសពីនេះទៅទៀត អង្គការលើកលែងទោសអន្តរជាតិមិនដែលឮថាមានការចាត់វិធានការផ្លូវច្បាប់ណាមួយប្រឆាំងនឹងមន្ត្រីណាដែលសង្ស័យថាបានប្រព្រឹត្តនៅក្រៅរង្វង់ច្បាប់ដែលទាក់ទងទៅនឹងករណីទាំងនេះឡើយ។

## មន្ត្រីសិទ្ធិមនុស្ស

### អ្នកឃ្លាំមើលសិទ្ធិមនុស្ស

សិទ្ធិសេរីភាពក្នុងការប្រជុំត្រូវបានចែងនៅក្នុងមាត្រាទី២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិង សិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាត្រូវមានកាតព្វកិច្ចលើកកំពស់សិទ្ធិនេះ។ មាត្រានេះផ្តល់សម្រាប់ការដាក់កំរិតសិទ្ធិនេះរួមមាន "ជាប្រយោជន៍ដល់សន្តិសុខជាតិឬសុវត្ថិភាពសាធារណៈ សណ្តាប់

ផ្ទាប់សាធារណៈ ការការពារសុខភាពសាធារណៈ សីលធម៌ឬការការពារសិទ្ធិសេរីភាពរបស់អ្នកដទៃ។" ទោះយ៉ាងណាក៏ដោយ អង្គការលើកលែងទោសអន្តរជាតិព្រួយបារម្ភថា អាជ្ញាធរនៃប្រទេសកម្ពុជាបានរំលោភលើសិទ្ធិនេះដោយបដិសេធចោលនៅក្នុងកាលៈទេសៈមួយដែលការអនុវត្តសិទ្ធិនេះមិនត្រូវបានយកមកពិចារណាឡើយ ហើយដែលមាត្រា៤១នៃច្បាប់រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានធានានូវសិទ្ធិនេះផងដែរក៏ដោយ។

មន្ត្រីសិទ្ធិមនុស្សដឹងខ្លួនដែរថា ខ្លួនប្រឈមនឹងគ្រោះថ្នាក់ដោយសារការការពារសិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋាន គេបានដឹងថាកម្លាំងសន្តិសុខបានហាមឃាត់មេធាវីមិនអោយចូលទាក់ទងជាមួយកូនក្តីរបស់ពួកគេនៅក្នុងភូមិហើយនៅក្នុងខេត្តរតនៈគីរីនិងខេត្តមណ្ឌលគីរី អាជ្ញាធរខេត្តបានទាមទារលិខិតស្នើសុំការអនុញ្ញាតដើម្បីចុះសួរសុខទុក្ខសហគមន៍ដែលប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ឬដើម្បីឃ្លាំមើលការតវ៉ាដោយសន្តិវិធី។ អាជ្ញាធរបានរារាំងអ្នកឃ្លាំមើលសិទ្ធិមនុស្សជាប្រចាំមិនអោយចូលទៅកាន់ទីកន្លែងបណ្តេញចេញ។ នៅក្នុងខែឧសភា និងមិថុនា២០០៦ កម្លាំងសន្តិសុខបានរារាំងមន្ត្រីសិទ្ធិមនុស្សនិងអ្នកកាសែតមិនអោយចូលយកព័ត៌មាន អំពីការបណ្តេញចេញដោយបង្ខំនៅតំបន់សំបុកចាបនិងមន្ទីរពេទ្យមុនីវង្សក្នុងទីក្រុងភ្នំពេញ។[២១] ហើយនៅក្នុងខែវិច្ឆិកាឆ្នាំ២០០៧ កម្លាំងសន្តិសុខបានឡោមព័ទ្ធមិនអោយចេញចូលភូមិចុងជ្រោយ សង្កាត់ជ្រោយចង្វា នៅក្នុងខ័ណ្ឌឬស្សីកែវនៃទីក្រុងភ្នំពេញ ហើយបានរឹបអូសយកឧបករណ៍ថតរូប នៅពេលភូមិត្រូវបានបណ្តេញចេញដោយបង្ខំនៅក្នុងប្រតិបត្តិការ មុនពេលថ្ងៃរះ។[២២] ក្នុងខែដដែល មន្ត្រីសិទ្ធិមនុស្សមិនត្រូវបានអនុញ្ញាតឱ្យចូលមើលសហគមន៍ដែលទទួលរងការដុតបំផ្លាញ នៅក្នុងឃុំកន្ទួត ខេត្តព្រះវិហារឡើយ។

ជាទម្លាប់មន្ត្រីមូលដ្ឋានបដិសេធសំណើររបស់អង្គការសង្គមស៊ីវិលដែលសុំធ្វើការប្រជុំឬរៀបចំពិធីអ្វីមួយ។ នៅក្នុងឱកាសជាច្រើនសារ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានហាមមិនអោយធ្វើវេទិកាសាធារណៈស្តីពីសិទ្ធិដីធ្លីនិងការបណ្តេញចេញឡើយ រួមមាននៅក្នុងខេត្តក្រចេះ ខេត្តស្វាយរៀង និងខេត្តរតនៈគីរី នេះគឺយោងតាមមន្ត្រីរបស់អង្គការនេះបាននិយាយប្រាប់អង្គការលើកលែងទោស

២១ សូមអានរបាយការណ៍ "*សិទ្ធិមនុស្សត្រូវបានគេរំលោភ — ការបណ្តេញចេញដោយបង្ខំនៅព្រះរាជាណាចក្រកម្ពុជា*" អង្គការលើកលែងទោស អន្តរជាតិ ២០០៨ និង របាយការណ៍ "ការវាយប្រហារនិងការគំរាមកំហែងអ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជាឆ្នាំ២០០៦" អង្គការលីកាដូ ខែធ្នូឆ្នាំ២០០៦។

២២ សូមមើលៈ *អង្គការលើកលែងទោសអន្តរជាតិៈ កម្ពុជាៈ ការបណ្តេញចេញដោយបង្ខំ វិធានការជាបន្ទាន់* ថ្ងៃទី២២ខែវិច្ឆិកាឆ្នាំ២០០៧ [http://www.amnesty.org/en/library/asset/ASA23/009/2007/en/dom-ASA230092007en.html]

អន្តរជាតិ។[២៣] ក្នុងខេត្តរតនៈគិរី អាជ្ញាធរមូលដ្ឋាន បានធ្វើការរារាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា វិទ្យុសម្លេងប្រជាធិបតេយ្យ និងអ្នកឯទៀត មិនអោយ ធ្វើវេទិកាសាធារណៈស្តីពីសិទ្ធិដីធ្លី នៅក្នុងឬនៅជិតភូមិគងយុ ដោយគ្មានផ្តល់ការពន្យល់ណាមួយឡើយ។ នៅ ថ្ងៃទី៣ ធ្នូ ២០០៧ ប៉ូលិស យោធាប្រដាប់ដោយអាវុធ និងអភិបាលស្រុក បានបញ្ឈប់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា គឺលោកសាស្ត្រាចារ្យ យ៉ាសហ៊ី ហ្គាយ និងបុគ្គលិកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយបានសួរនាំអំពីមូលហេតុ ដែលពួកគាត់មិនបានស្វែងរកលិខិតអនុញ្ញាតជាមុនដើម្បីចូលសួរសុខទុក្ខ។[២៤]

មាត្រាទី១២នៃសេចក្តីប្រកាសរបស់សហប្រជាជាតិស្តីអំពីអ្នកការពារសិទ្ធិមនុស្ស គូសបញ្ជាក់ថា "ជនគ្រប់រូប ដោយម្នាក់ៗឯងក្តីនិងដោយរួមជាមួយអ្នកដទៃក្តី មានសិទ្ធិចូលរួមធ្វើសកម្មភាពដោយសន្តិវិធី ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន "ហើយបញ្ជាក់ទៀតថារដ្ឋត្រូវ" ចាត់វិធានការ ចាំបាច់ដើម្បីធានាអោយមាននូវការការពារពីអាជ្ញាធរមានសមត្ថកិច្ចចំពោះជនគ្រប់រូប ដោយម្នាក់ឯងក្តីនិងដោយរួមជាមួយអ្នកដទៃក្តី ប្រឆាំងនឹងអំពើហិង្សា ការគំរាមកំហែង ការសងសឹក ការរើសអើងក្នុងការអនុវត្តជាក់ស្តែងនិងតាមផ្លូវច្បាប់ ការគៀបសង្កត់ ឬសកម្មភាពតាមអំពើចិត្តផ្សេងៗទៀត ដោយសារតែការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន ដែលមានចែងក្នុងសេចក្តីប្រកាសនេះ។"

ទោះជាយ៉ាងណាក៏ដោយ មន្ត្រីសិទ្ធិមនុស្សដែលការពារសិទ្ធិសហគមន៍ដែលត្រូវបណ្តេញចេញ ដោយបង្ខំត្រូវបានយាយីនិងបំភិតបំភ័យអំឡុងពេលបំពេញការងាររបស់ខ្លួន។ មានឧទាហរណ៍ច្រើន ដែលអាជ្ញាធរ ឬកម្លាំងសន្តិសុខបាននាំខ្លួនអ្នកឃ្លាំមើលសិទ្ធិមនុស្សមកសួរនាំឬគំរាមពួកគេ ក្នុងបរិបទនៃការបណ្តេញចេញ ជាឧទាហរណ៍ ដូចជាការឃាត់ខ្លួនមន្ត្រីសិទ្ធិមនុស្សបួននាក់ពីអង្គការលីកាដូ អាដហុក និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅក្នុងខែឧសភាឆ្នាំ២០០៦ ក្នុងស្រុកឈូកខេត្តកំពត។ នៅពេលពួកគេកំពុងព្យាយាមឃ្លាំមើលហេតុការណ៍មួយក្នុងឃុំត្រពាំងប្លុំង ដែលកម្លាំងសន្តិសុខ បានដុតផ្ទះប្រហែល ២០ខ្នង ប៉ូលិស កងរាជអាវុធហត្ថ និងយោធា បានឡោមព័ទ្ធអ្នកទាំងបួន ដោយភ្ជង់កាំភ្លើង ហើយបាន រឹបអូសយកម៉ាស៊ីនថតរូបនិងបង្ខំពួកគេអោយចាកចេញពីទីកន្លែង។

---

២៣ ប្រជុំជាមួយមជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា

២៤ *របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា យ៉ាសហ៊ី ហ្គាយ A/HRC/7/42; ថ្ងៃទី២៩ខែកុម្ភៈឆ្នាំ២០០៨ កថាខ័ណ្ឌ៧០*

ម្នាក់ក្នុងចំណោមទាំងបួននាក់គឺ ឈឹម សាវ៉ុធ ដែលជាអ្នកសង្កេតការសិទ្ធិមនុស្សរបស់អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មួយឆ្នាំក្រោយមកត្រូវបានគំរាមកំហែងដោយសារសកម្មភាពរបស់គាត់នៅក្រុងកំពង់សោម។ ក្នុងឆ្នាំ២០០៦ អាជ្ញាធរក្រុងបានប្រាប់គាត់ថាភូមិមិត្តភាព៤ ឬហៅភូមិស្ពានឆេះ តម្រូវអោយចុះបញ្ជីជាសហគមន៍ ដើម្បីរួមគ្នាតែងតាំងអ្នកតំណាងម្នាក់ ក្នុងជម្លោះដីដែលកើតមាន។ ឈឹម សាវ៉ុធ បានជួយសហគមន៍លើបញ្ហាក្រដាសស្នាម។ ជំនួយនេះ មិនបានជួយបញ្ចៀសការបណ្តេញចេញដោយបង្ខំទេ។ គឺនៅថ្ងៃទី២០ខែមេសាឆ្នាំ២០០៧ ១០៥គ្រួសារ ក្នុងភូមិនៅក្រុងព្រះសីហនុបានក្លាយជាអ្នកគ្មានផ្ទះសម្បែង នៅពេលប៉ូលិស យោធា និងកងរាជអាវុធហត្ថបានដុតនិងឈូសផ្ទះរបស់ពួកគេ។ អ្នកភូមិ១៣នាក់ត្រូវបានចាប់ ខ្លួន។[២៥]

ហេតុការណ៍នេះ បានទាក់ទាញប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានក្នុងស្រុកនិងទទួលប្រតិកម្មជាច្រើន រួមមានពីអង្គការ លើកលែងទោសអន្តរជាតិ និងរដ្ឋាភិបាលបរទេស។ ប៉ុន្មានសប្តាហ៍ក្រោយមក ឈឹម សាវ៉ុធត្រូវបានព្រមានដោយប្រភពច្បាស់លាស់មួយថាគាត់គួរលាក់ខ្លួនដើម្បីគេចពីការពីការចាប់ខ្លួនដែលប្រុងនឹងកើតឡើង។ ប្រភពនោះបានប្រាប់គាត់ថាមន្ត្រីជាន់ខ្ពស់ ម្នាក់នៅក្រុងព្រះសីហនុបានធ្វើការប្រជុំមួយជាមួយអធិការជាច្រើនរូបមកពីក្រសួងមហាផ្ទៃបានស្នើសុំចាប់ខ្លួនគាត់។ នៅថ្ងៃទី០៧ ឧសភា ២០០៧ អតីតអភិបាលក្រុង សាយ ហាក់ បាននិយាយប្រាប់អ្នកសារព័ត៌មានថាគាត់បានបញ្ជូនភស្តុតាងទៅកាន់តុលាការក្រុងព្រះសីហនុ ដែលបង្ហាញថា ឈឹម សាវ៉ុធ បាន "ហៅអ្នកភូមិ អោយបង្កើតតំបន់ឯករាជ្យបំបែកចេញពីការគ្រប់គ្រងរបស់រដ្ឋាភិបាល"។[២៦]

ក្រោយមកមន្ត្រីតុលាការបានអះអាងដល់អង្គការសិទ្ធិមនុស្សពីរថា ពួកគាត់ពិតជាបានទទួលពាក្យបណ្តឹងពីអតីតអភិបាលក្រុង សាយ ហាក់ ដែលចោទប្រកាន់ ឈឹម សាវ៉ុធ ថាបានញុះញង់អ្នកភូមិអោយបង្កើតតំបន់ឯករាជ្យមែន។

---

២៥ សូមមើល *កម្ពុជា: ធ្វើអោយអ្នកក្រគ្មានផ្ទះសម្បែង (ធ្វើបច្ចុប្បន្នភាព)* អង្គការលើកលែងទោសអន្តរជាតិ-ខែឧសភាឆ្នាំ២០០៨- *សិទ្ធិមនុស្សត្រូវ គេរំលោភ-ការបណ្តេញចេញដោយបង្ខំនៅព្រះរាជាណាចក្រកម្ពុជា* អង្គការលើកលែងទោសអន្តរជាតិឆ្នាំ២០០៨ និងការវាយប្រហារ

២៦ *អភិបាលក្រុងព្រះសីហនុ : មន្ត្រីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានញុះញង់អ្នកភូមិ*-កាសែត ឌឹ ឃែមបូឌា ដេលី ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៧



© LICADHO

*ឈឹម សាវុធបានព្យាយាមជួយសហគមន៍ ដែលប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ពេលដែលគាត់ទទួលការ គំរាមដោយប្រយោល ។ អ្នកភូមិ១៣នាក់ត្រូវបានចាប់ខ្លួន នៅពេលបណ្តេញចេញ ។*

នៅពេលឮអំពីបទចោទប្រកាន់ធ្ងន់ធ្ងរមកលើរូបគាត់ និងពេលទទួលការព្រមានអំពីការថានិងត្រូវចាប់ខ្លួន សាវុធបានទៅលាក់ខ្លួនតាមខេត្តផ្សេងៗដូចជា ខេត្តកោះកុង ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ ។ គាត់បាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិថាៈ- *"ខ្ញុំបានឈប់ធ្វើការរយៈពេលពីរខែ ។ ខ្ញុំបានបិទទូរស័ព្ទ ដែលគ្មានអ្នកណាម្នាក់អាចទាក់ទងខ្ញុំបានឡើយ ។ ខ្ញុំប្រើតែទូរស័ព្ទសាធារណៈ"*

ក្រោយមកបទចោទប្រកាន់បានរសាយចុះបន្តិចម្តងៗ ។ ឈឹម សាវុធបាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិថាបទអន្តរាគមន៍របស់គណៈកម្មាការសិទ្ធិមនុស្សអាស៊ីមានប្រសិទ្ធិភាពគួរអោយកត់សម្គាល់ ។[២៧] *"ក៏ប៉ុន្តែខ្ញុំនៅគិតក្នុងចិត្តថាពាក្យបណ្តឹងនៅតំកល់ទុកនៅឡើយ ។ ខ្ញុំនៅតែបារម្ភថានៅថ្ងៃណាមួយ នៅពេលខ្ញុំធ្វើសកម្មភាពម្តងទៀត គេនឹងយកបញ្ហានេះមកពិចារណា ។ ពួកគេមិនងាយដកពាក្យបណ្តឹង បែបនេះដោយងាយៗទេ ប៉ុន្តែអាចព្យួរទុកវាដោយរង់ចាំឱកាសផ្សេងទៀត(...)"*

ឈឹម សាវុធ នៅបន្តធ្វើការជាអ្នកស៊ើបអង្កេតសិទ្ធិមនុស្ស ប៉ុន្តែឥឡូវប្រចាំការនៅភ្នំពេញ ហើយគាត់ទៅក្រុងព្រះសីហនុម្តងម្កាលដោយនៅតែមានមានការព្រួយបារម្ភជាប់ជានិច្ច ។
គាត់បាននិយាយ ប្រាប់អង្គការលើកលែងទោសអន្តរជាតិថាៈ

២៧ *អ្នកស៊ើបអង្កេតសិទ្ធិមនុស្សម្នាក់និងអ្នកភូមិ៥នាក់កំពុងជាប់ចោទពីបទព្យុះញុងបង្កើតតំបន់អបគមន៍*-គណកម្មការសិទ្ធិមនុស្សអាស៊ី ថ្ងៃទី១០ ខែឧសភាឆ្នាំ២០០៧

*"ខ្ញុំលាក់មុខបន្តិចបន្តួចដែរ ។ ខ្ញុំនៅតែព្រួយបារម្ភអញ្ចឹង ។ ខ្ញុំមិនបារម្ភត្រូវគេចាប់ខ្លួនខ្លាំងពេកទេ ប៉ុន្តែខ្ញុំខ្លាចក្រែងមានផែនការសម្លាប់ ដូចជាគ្រោះថ្នាក់ចរាចរ ឬអំពើប្លន់ដើម្បីបំបាត់ភស្តុតាង ។ ខ្ញុំមិនសូវ បារម្ភទេប្រសិនបើគេចាប់ខ្លួនខ្ញុំ ។ ប្រសិនបើប្រជាជនធម្មតាចូលគុក ខ្ញុំក៏អាចដែរ ។"*



© Amnesty International

*ឈឹម សាវុធបានលាក់ខ្លួនរយៈពេលពីរខែបន្ទាប់ពីការព្រមានចាប់ខ្លួន ។*

## មេធាវីជំនួយផ្នែកច្បាប់

មេធាវីជំនួយផ្នែកច្បាប់គឺជាក្រុមអ្នកការពារសិទ្ធិមនុស្សផ្សេងទៀត ដែលបានទទួលការគំរាមកំហែង ខណៈដែលបំពេញការងារជួយជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ ឬជម្លោះដីធ្លី ។

ឧទាហរណ៍មេធាវីតំណាងអោយជនជាតិដើមភាគតិចចារ៉ាយក្នុងភូមិគងយុនិងភូមិគងធំ ។ នៅក្នុងពាក្យបណ្តឹងពីបទព្រហ្មទណ្ឌដែលបានប្តឹងតំណាងអ្នកភូមិដូចបានបញ្ជាក់ខាងលើ អ្នកប្តឹងគឺអ្នកស្រី គាត កុលណើ បានរាប់បញ្ចូលមេធាវីចំនួនដប់នាក់តំណាងអោយករណីនោះ ដោយចោទប្រកាន់ពួកគេពីបទញុះញង់ បន្លំនិងបង្ខូចកេរ្តិ៍ឈ្មោះ មេធាវីប្រាំពីរនាក់ក្នុងចំណោមមេធាវីទាំងនោះ ធ្វើការនៅមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ហើយបីនាក់ទៀតធ្វើការនៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលអង្គការទាំងពីរជា អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ។

លោក ផៃ វិបុល ដែលជាមេធាវីរបស់ គាត កុលណើ បានបញ្ជាក់ដល់អង្គការលើកលែងទោសអន្តរជាតិថា ពាក្យបណ្តឹងប្តឹងរួមទាំងមេធាវីទាំងនោះ ។ បើតាម ផៃ វិបុល ថាមានមេធាវីពីរឬបីនាក់ក្នុងចំណោមមេធាវីទាំងដប់នាក់ ត្រូវបានប្តឹង ក៏ប៉ុន្តែទោះយ៉ាងនេះក៏ដោយ វាជាឱកាសសម្រាប់ព្រះរាជអាជ្ញាតុលាការខេត្តធ្វើការស៊ើបអង្កេតពីបទព្រហ្មទណ្ឌ ដើម្បីចោទពួកគេទាំងអស់គ្នា ។ គេបានរាយការណ៍ថា ការស៊ើបអង្កេតកំពុងតែបន្តធ្វើ ។

អ្នកស្រី គាត កុលណី បានសរសេរលិខិតទៅកាន់ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដោយបានដាក់ឈ្មោះមេធាវីនីមួយៗរបស់អង្គការ និងចោទប្រកាន់ពួកគេពីការញុះញង់ និងប្រព្រឹត្តដោយហេតុផលរឿងនយោបាយ។ គាត់បានស្នើសុំប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាអោយ "ចាត់វិធានការតាមផ្លូវច្បាប់ដើម្បីស៊ើបអង្កេត"។[២៨] ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានហៅមេធាវីប្រជុំ ក៏ប៉ុន្តែបានប្រកែកជាសាធារណៈថា គាត់មិនបានដាក់ពួកគេអោយស្ថិតនៅក្រោមការស៊ើបអង្កេតណាមួយឡើយ។

ក្នុងខែតុលាឆ្នាំ២០០៧ មេធាវីរបស់អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថាប៉ូលិសស្រុកបានរារាំងមេធាវីមិនអោយចូលជួបកូនក្តីរបស់ខ្លួនក្នុងភូមិគងឃុ ដោយផ្អែកលើមូលដ្ឋានថា ប៉ូលិសមិនអាចធានានូវសុវត្ថិភាពមេធាវីក្នុងភូមិបានទេ។ បន្ទាប់ពីមានបទអន្តរាគមន៍ពីមន្ត្រីម្នាក់ ពីក្រសួងមហាផ្ទៃ ប៉ូលិសបានអនុញ្ញាតអោយមេធាវីជួបកូនក្តីរបស់ខ្លួននៅថ្ងៃបន្ទាប់។

នៅថ្ងៃទី១ខែសីហាឆ្នាំ២០០៨ ចៅក្រមជំនុំជម្រះបានហៅមេធាវីមកកាន់តុលាការ។ គាត់បាននិយាយប្រាប់ពួកគេថាគាត់មិនគំរាមកំហែងទេ ប៉ុន្តែថាការស៊ើបអង្កេតពីបទព្រហ្មទណ្ឌទៅលើមេធាវីមិនទាន់បញ្ចប់នៅឡើយទេ។ ចៅក្រមជំនុំជម្រះក៏បានព្រមានពួកគេផងដែរ សុំអោយប្រុងប្រយ័ត្នអំពីការផ្តល់ព័ត៌មានដល់អ្នកសារព័ត៌មាន បើពុំដូច្នោះទេ ពួកគេអាចប្រឈមមុខនឹងការចោទប្រកាន់ពីបទបរិហាកេរ្តិ៍។

បួនថ្ងៃក្រោយមក មេធាវីបានប្តឹងសុំអោយដកចៅក្រមជម្រះក្តីពីសវនាការ ដោយករណីថាមិនបានយកចិត្តទុកដាក់បំពេញកាតព្វកិច្ចតុលាការរបស់ខ្លួន មានភាពលំអៀង និង មិនបំពេញភារកិច្ចក្នុងការរកដំណោះស្រាយលើជម្លោះទៅតាមច្បាប់។

ចាប់តាំងពីបានដាក់ពាក្យបណ្តឹងក្នុងខែមិថុនាឆ្នាំ២០០៧មក មេធាវីប្រាំបីនាក់លែងធ្វើការលើករណី នេះទៀតហើយ។ ចំណែកមេធាវីឯទៀតបានចាប់យកការងារផ្ទាល់ខ្លួន។

## សេចក្តីសន្និដ្ឋាន

ពេលមានជម្លោះនៅស្រុកបាវិលខេត្តបាត់ដំបង អឿន សារីម ដែលជាប្រពន្ធ ឈា នី ក៏បានឡើងធ្វើជាតំណាងសហគមន៍បឹងប្រាំ ហើយជាសមាជិកបណ្តាញក្រៅផ្លូវការនៃសកម្មជនទូទាំងប្រទេស។

[២៨] ឯកសាររបស់អង្គការលើកលែងទោសអន្តរជាតិដែលមិនបានបោះពុម្ពផ្សាយ ថ្ងៃទី១៩ខែមិថុនាឆ្នាំ២០០៧

សម្រាប់រូបគាត់ ការដាក់ពន្ធនាគារប្ដីរបស់គាត់មិនមែនត្រឹមតែជាការព្រួយបារម្ភ របស់អ្នកភូមិរបស់គាត់ប៉ុណ្ណោះទេ ។

គាត់បាននិយាយប្រាប់អង្គការលើកលែងទោសអន្តរជាតិថា៖-"*ករណីប្ដីង ឈា នី គឺជាការវាយប្រហារផ្លូវចិត្តប្រជាជនទាំងអស់នៅទូទាំង២១ខេត្តដែលមានបញ្ហាដូចៗគ្នា ដើម្បីធ្វើអោយពួកគាត់ខ្លាច ។ ចាប់មនុស្សម្នាក់ គឺដើម្បីគំរាមមនុស្សរាប់ម៉ឺននាក់ ធ្វើអោយពួកគេខ្លាចលែងហ៊ានតស៊ូនិងលែងហ៊ានធ្វើការតស៊ូមតិតទៅទៀត ។ ខ្ញុំយល់ថាវា ជាអំពើអយុត្តិធមិសម្រាប់ប្រជាជនកម្ពុជា*"។

ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនសកម្មជនជាប់ពន្ធនាគារ ដោយសារការតវ៉ាដោយសន្តិវិធី ធ្វើអោយអង្គការលើកលែងទោសអន្តរជាតិមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ ។ ក៏ប៉ុន្តែ ដូចដែល អឿន សារីម បានបញ្ជាក់នោះ វាក៏ជាឧបករណ៍បំភិតបំភ័យមួយចំពោះអ្នកការពារសិទ្ធិមនុស្សដទៃទៀត ដោយធ្វើការគំរាមកំហែងជាក់ស្ដែងមកលើពួកគេនូវការឃុំឃាំង ការកាត់ទោស និងដាក់ពន្ធនាគារ ។

ទាក់ទងទៅនឹងវិធានការច្បាប់ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ការខ្វះខាតសេចក្ដីសុច្ចរិតរបស់ស្ថាប័នច្បាប់និងការខ្វះខាតសមភាពចំពោះមុខច្បាប់ ធ្វើការដកហូតការការពារពីពួកគេ ដែលប្រព័ន្ធច្បាប់កំណត់ថាត្រូវផ្ដល់ការធានា។ តាមការពិតទៅ ស្ថាប័នច្បាប់ដើរតួនាទីចំបងក្នុងការរំលោភសិទ្ធិមនុស្សរបស់ពួកគេ និងសិទ្ធិរបស់អ្នកដទៃដែលពួកគេតំណាងអោយ ។ តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា បានឆ្លុះបញ្ចាំងពីបញ្ហានេះក្នុងរបាយការណ៍ថ្មីបំផុតរបស់គាត់ ស្ដីអំពីការខ្វះខាតឯករាជ្យភាពនៃស្ថាប័នអយ្យាការ ដែលបានឆ្លុះបញ្ចាំងក្នុងករណីដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ៈ-

"*បទល្មើសដែលមានចែងក្នុងច្បាប់អំពីការរំលោភសិទ្ធិដីធ្លី មិនត្រូវបានគេប្រើប្រាស់ដើម្បីការពារសហគមន៍ដែលសិទ្ធិរបស់ពួកគេត្រូវអ្នកមានអំណាច ក្រុមហ៊ុនឬអង្គភាពរដ្ឋាភិបាលរំលោភបំពានឡើយ ។ មិនមានការចាត់វិធានការទៅលើអ្នកដែលបានលក់ឬបានទិញដីអ្នកដទៃដោយខុសច្បាប់ ឬដែលបានរំលោភសិទ្ធិ ដីធ្លីរបស់ពួកគេ និងធនធានព្រៃឈើ ។*"

"*ផ្ទុយទៅវិញ នៅពេលមានបណ្ដឹងទៅតុលាការប្រឆាំងនឹងអ្នកមានអំណាច ឬក្រុមហ៊ុន (ឬនៅពេលដែលសហគមន៍តវ៉ានឹងការបណ្ដេញចេញ ឬការទាមទារដីធ្លីរបស់ខ្លួនមកវិញ) តាមធម្មតាដើមចោទត្រូវបានចោទប្រកាន់ ពីបទល្មើសណាមួយទៅវិញ ជាអាទិ៍ "ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ" ឬ*

*"ការរំលោភលើទ្រព្យសម្បត្តិអ្នកដទៃ"។ ជាលទ្ធផលនៃការចោទប្រកាន់នេះ អាចធ្វើអោយជននោះជាប់ឃុំឃាំង ហើយមិនអាចធ្វើការទាមទារសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់តទៅទៀតបានឡើយ។"*[២៩]

នៅក្នុងរបាយការណ៏របស់គាត់ក្នុងឆ្នាំ២០០៦ស្ដីអំពីប្រទេសកម្ពុជា មីលូន កូតារី អ្នករាយការណ៏ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានក៏រិតជីវភាពសមរម្យ បានកត់សំគាល់ថាមានការលេចឡើងការបំភិតបំភ័យ និងគំរាមកំហែង ពីអាជ្ញាធរមូលដ្ឋាន និងអ្នកអភិវឌ្ឍន៏ឯកជន ដែលឈានទៅរកកិច្ចព្រមព្រៀងដីដ៏សង្ស័យនិង ការបណ្ដេញចេញ រួមមាន *"ការគំរាមកំហែងប្រើប្រាស់កម្លាំង ការផ្ដល់ព័ត៌មានមិនពិតនិងពាក្យចចាមអារាមទំលាក់កំហុសដាក់លើអ្នកតំណាងថាមានពាក់ព័ន្ធក្នុងរឿង"នយោបាយ" ឬចោទថា បានប្រព្រឹត្តបទឧក្រិដ្ឋ ក៏ដូចជាការរិតត្បិត ដល់ក្រុមគ្រួសារដែលទទួលរងគ្រោះ ក្នុងការចេញចូលផ្ទះ របស់ពួកគេ និងការបន្ទុចបង្អាក់អ្នកភូមិមិនអោយមានការរួមប្រជុំជាដើម"*។[៣០] ពីរឆ្នាំក្រោយមក ការគំរាមបែបនេះបានវិវត្តទៅជា *វិធីសាស្ត្រអនុវត្ត* មួយដើម្បីប្រឆាំងនឹងបុគ្គលនិងក្រុមណា ដែលការពារសិទ្ធិទាក់ទងទៅនឹងដីធ្លីនិងលំនៅដ្ឋាន។ នៅក្នុងខណៈពេលនេះ អ្នកទាំងនោះដែលនៅពីក្រោយការគំរាមកំហែងនិងសកម្មភាពធ្វើប្រតិបត្តិការយ៉ាងរាលដាលដោយគ្មានទោសឡើយ។

ទោះជាយ៉ាងនេះក្ដី ការវិវត្តន៏ជាវិជ្ជមានកើតមានឡើង។ សកម្មជនដីធ្លីកម្ពុជាកាលពីមុនមិនធ្លាប់ប្រមូលផ្ដុំគ្នាដូចសព្វថ្ងៃនេះទេ។ បណ្ដាញក្រៅផ្លូវការនៃជនរងគ្រោះដោយបណ្ដេញចេញដោយបង្ខំ កំពុងក្រោកឡើងហើយម្នាក់ៗចែករំលែកបទពិសោធន៏ និងពិភាក្សាគ្នារកដំណោះស្រាយ រួមមាន ការដោះស្រាយការរំលោភសិទ្ធិមនុស្សជាដើម។

## **អនុសាសន៏**

អង្គការលើកលែងទោសអន្តរជាតិធ្វើការអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាសូមអោយៈ-

- គោរពនិងការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស

  រួមទាំងអ្នកដែលធ្វើការលើផ្នែកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីពួកគេធ្វើការ

---

[២៩] របាយការណ៏របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា យ៉ាសហ៊ី ហ្គាយ UN doc. A/HRC/7/42, ថ្ងៃទី២៩ខែកុម្ភៈឆ្នាំ២០០៨ កថាខ័ណ្ឌ៣៤-៥

[៣០] របាយការណ៏របស់អ្នករាយការណ៏ពិសេសទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យដែលជាផ្នែកមួយនៃសិទ្ធិមានជីវភាពសមរម្យ —់ មីលូន កូតារី បំពេញបេសកកម្មមកកាន់ប្រទេសកម្ពុជា A/HRUN Doc.E/CN.4/2006/41/Add.3,21 March 2006, para. 61

ដោយពុំមានការរារាំង ការបំភិតបំភ័យឬយាយី ស្របតាមសេចក្តី ប្រកាសសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស [៣១]

- ធានាថាអ្នកដែលជំរុញលើកកំពស់និងការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិដទៃទៀតដែលផ្សារភ្ជាប់នឹងការបណ្តេញចេញដោយបង្ខំនិងជម្លោះដីធ្លី អាចធ្វើការ ដោយសេរី ហើយធានាអោយបានផងដែរនូវការបញ្ចប់ការបណ្តេញចេញដោយបង្ខំ។
- ថ្កោលទោសជាសាធារណៈដល់ការវាយប្រហារលើអ្នកការពារសិទ្ធិមនុស្ស និងធ្វើការប្តេជ្ញាជាសាធារណៈថា នឹងពុំមានការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សបន្ថែមទៀត ឬបុគ្គលឯទៀតដែលចូលរួមដោយបរិសុទ្ធ នៅក្នុងការអនុវត្តសិទ្ធិសេរីភាពរបស់ពួកគេក្នុងការបញ្ចេញមតិ ជំនឿ ការបញ្ចេញមតិនិងចូលរួមសមាគម។
- ដាក់ចេញគោលការណ៍ណែនាំច្បាស់លាស់ដល់មន្ត្រីអនុវត្តច្បាប់ ស្តីពីសិទ្ធិសេរីភាពបញ្ចេញមតិការប្រជុំនិងចូលរួមជាសមាគម ដោយស្របតាមបទដ្ឋានអន្តរជាតិ និងណែនាំមន្ត្រីប្រតិបត្តច្បាប់ទាំងអស់នៅគ្រប់ថ្នាក់ អំពីកាតព្វកិច្ចរបស់ពួកគេ អោយគោរពនិងការពារសិទ្ធិមនុស្ស និងធ្វើអោយច្បាស់ថាពួកគេនឹងត្រូវទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សដែលពួកគេបានប្រព្រឹត្ត។
- ធានាថារាល់ការរំលោភសិទ្ធិមនុស្សទាំងអស់ទៅលើអ្នកការពារសិទ្ធិមនុស្ស រួមមានអ្នកតំណាង សហគមន៍ មេធាវី និងអ្នកឃ្លាំមើលសិទ្ធិមនុស្ស ត្រូវស៊ើបអង្កេតជាបន្ទាន់ ដោយល្អិតល្អន់ ដោយឯករាជ្យ និងដោយមិនលំអៀង ហើយត្រូវនាំខ្លួនជនល្មើសដែលបានរំលោភបំពាននោះទៅតុលាកការដើម្បីកាត់ទោសតាមច្បាប់។
- សំណូមពរដល់អ្នករាយការណ៍ពិសេសទទួលបន្ទុកអ្នកកាពារសិទ្ធិមនុស្សអោយធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ដើម្បីស៊ើបអង្កេតករណីបទល្មើសត្រូវបានចោទប្រកាន់ទាំងអស់លើអ្នកការពារសិទ្ធិមនុស្សក្នុងបរិបទ នៃ ការបណ្តេញចេញដោយបង្ខំ និងសិទ្ធិដីធ្លី។

---

[៣១] ដូចបានបញ្ជាក់ក្នុងរបាយការណ៍អង្គការលើកលែងទោសអន្តរជាតិ *សិទ្ធិមនុស្សដែលត្រូវគេរំលោភ-ការបណ្តេញចេញដោយបង្ខំនៅព្រះរាជាណា ចក្រកម្ពុជា* ថ្ងៃទី១១ខែកុម្ភៈឆ្នាំ២០០៨ ទំព័រ៤៧។
សូមមើលរបាយការណ៍នេះអំពីអនុសាសន៍របស់អង្គការលើកលែងទោសអន្តរជាតិ ដែលទាក់ទងនឹង ការបណ្តេញចេញដោយបង្ខំ។
អង្គការសូមអំពាវនាវអោយបញ្ឈប់ជាបន្ទាន់នូវការបណ្តេញចេញដោយបង្ខំ និងការបង្អាក់ការបណ្តេញចេញជាទ្រង់ទ្រាយធំដរាបណាការហាមឃាត់ដោយស្របច្បាប់នូវការបណ្តេញចេញដោយបង្ខំត្រូវបានជំនួសនិងអនុវត្ត ហើយគោលការណ៍ណែនាំសម្រាប់ការបណ្តេញចេញដែលអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ត្រូវបានអនុម័ត។